អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦

# សេចក្តីថ្លែងការណ៍របស់អង្គភាពគាំពារការការពារក្តី

អង្គភាពគាំពារការការពារក្តី (“អ.គ.ក”) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចាត់តាំងលោក Wayne Jordash មេធាវីជាន់ខ្ពស់របស់ចក្រភពអង់គ្លេស ជាសហមេធាវីបរទេសតំណាងឲ្យអ្នកស្រី អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/០១។

លោក Jordash គឺជាមេធាវីប្រចាំនៅទីក្រុងឡុងដ៍ ដែលមានជំនាញផ្នែកឧក្រិដ្ឋកម្មអន្តរជាតិ និងបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងៗទៀត។ គាត់បានក្លាយជាមេធាវីនៃប្រទេសអង់គ្លេស និងវេលស៍ ក្នុងឆ្នាំ ១៩៩៥ ហើយបានក្លាយជាមេធាវីជាន់ខ្ពស់ (Queen’s Counsel) តាំងពីឆ្នាំ ២០១៤។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់គាត់ឲ្យប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក។ លោក Jordash មានបទពិសោធន៍ទូលំទូលាយនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការអន្តរជាតិ ដោយបានតំណាងឲ្យចុងចម្លើយនានានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ាន់ដា និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន។ គាត់ក៏បម្រើការនៅ អ.វ.ត.ក ផងដែរ ជាមន្ត្រីពិគ្រោះផ្នែកច្បាប់ឲ្យអង្គភាពគាំពារការការពារក្តី កាលពីឆ្នាំ ២០០៨-២០០៩។ មុនពេលផ្តោតសម្រួចទៅលើច្បាប់អន្តរជាតិ លោក Jordash បានប្រកបវិជ្ជាជីវៈការពារក្តីក្នុងរឿងក្តីព្រហ្មទណ្ឌជាច្រើននៅតុលាការប្រទេសអង់គ្លេស។ ក្រៅពីកិច្ចការការពារក្តីក្នុងរឿងក្តីព្រហ្មទណ្ឌរបស់គាត់នោះ គាត់បានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ទៅឲ្យបណ្តារដ្ឋ និងអង្គការអន្តរជាតិមួយចំនួន ស្តីអំពីសិទ្ធិមនុស្សអន្តរជាតិ ច្បាប់មនុស្សធម៌ និងច្បាប់ព្រហ្មទណ្ឌ។ គាត់ក៏បានធ្វើបទបង្ហាញ និងបានបោះពុម្ពផ្សាយយ៉ាងច្រើនផងដែរស្តីអំពីបញ្ហាទាំងនេះ។

លោក Jordash នឹងតំណាងឲ្យអ្នកស្រី អ៊ឹម ចែម រួមជាមួយនឹងលោក ប៊ិត ស៊ាងលីម ដែលត្រូវបានចាត់តាំងជាសហមេធាវីជាតិរបស់អ្នកស្រី កាលពីខែ ធ្នូ ឆ្នាំ ២០១៣ ។ លោក Jordash នឹងជំនួសលោក John Jones ដែលបានទទួលមរណភាពកាលពីខែ មេសា ឆ្នាំ ២០១៦។ ចំពោះការចាត់តាំងនេះ អង្គភាពគាំពារការការពារក្តី បានពិចារណាទៅលើការចង់បានរបស់អ្នកស្រី អ៊ឹម ចែម និងលិខិតបដិសេធអំពីទំនាស់ផលប្រយោជន៍ទាំងអស់ជាធរមាន។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

Original EN: 01300188-01300188